[redacted]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តបាត់ដំបង**

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥៤២
ចុះថ្ងៃទី២៨-០៨-២០១៧
សំណុំរឿងជម្រះ
លេខ ២៥៤
ចុះថ្ងៃទី០៧-០៥-២០១៨
សាលក្រម
លេខ "៤៦១ ឃ"
ចុះថ្ងៃទី១៩-០៧-២០១៨

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ ដោយមានសមាសភាពដូចតទៅ:

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបាត់ដំបង

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបាត់ដំបង

**ដើម្បីជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៥៤២ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ:

ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី១២ មុខរបរបើកឡានពេទ្យ កើតនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃផ្ទះលេខ៧៥៣ ក្រុម២៣ ភូមិទួលតាឯក សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង នៅលីវ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ រំលោភសេពសន្ថវៈ តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់បុរីថ្មី ភូមិអូរតាគាំ១ សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ។

ដោយមានលោក [redacted] ជាមេធាវីការពារជនជាប់ចោទ ។

ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ភេទស្រី អាយុ ២៥ឆ្នាំ ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី១២ មុខរបរនៅផ្ទះ កើតនៅភូមិរំចេក២ ឃុំស្វាយប៉ោ៣ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃផ្ទះលេខ៧១ ភូមិរំចេក២ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង នៅលីវ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ។

[redacted]

ខ្ញុំទៅយកគាត់នៅបេនឡានម៉ោង ១២:៣០ នាទីយប់ ។ គាត់ប្រាប់ខ្ញុំថា ទៅផ្ទះសំណាក់ទៅ ព្រោះគាត់ថាមិនបានប្រាប់អ្នកផ្ទះ ។ គោលបំណងខ្ញុំទទួលយកគាត់ហើយជូនទៅផ្ទះ ។ ប៉ូលីសប្រាប់ថារឿងប្ដឹងនៅស្នងការនេះជារឿងត្រូវរ៉ូវគ្នា ។ ក្រោយពេលមិនត្រូវរ៉ូវគ្នាគាត់ បានផុសតាមហ្វេសបុកមើលងាយខ្ញុំ និងក្រុមគ្រួសារ ។ ចំពោះការជេរប្រមាថមើលងាយនេះខ្ញុំក៏បានប្ដឹងនៅតុលាការនេះដែរ ។ ពេលចុះពីផ្ទះសំណាក់វិញ ខ្ញុំបានជូនទៅផ្ទះ ពុំមានការឆោឡោអ្វីទេ ៣ឆ្នាំក្រោយ ទើបមានបណ្ដឹង ។ ការដែលគាត់បញ្ជាក់ថាខ្ញុំឡើងទៅលើផ្ទះសំណាក់មុន ហើយគាត់ចាំ ១៥នាទី មិនជាការពិតទេ គឺឡើងដំណាលគ្នា ។ ខ្ញុំសូមបញ្ជាក់ថា ថ្ងៃឡើងផ្ទះសំណាក់បានអោបថើប ក្រោយមកទើបរួមភេទ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយថា ជនជាប់ចោទឆ្លើយទាំងបំពានទាំងមិនមែនជាការពិត ខ្ញុំស្គាល់គ្នារយៈពេល ១ឆ្នាំ រាប់អានគ្នាជាលក្ខណៈបងប្អូនមិត្តភក្ដិធម្មតា មិនមានការរួមភេទដូចគាត់ឆ្លើយទេ លើកលែងតែនៅថ្ងៃកើតហេតុ គឺគាត់ជាអ្នកទូរស័ព្ទមកសួរអំពីការធ្វើ ដំណើររបស់ខ្ញុំ គឺគាត់ជាអ្នកទទូចទៅផ្ទះសំណាក់ នៅពេលឡើងទៅដល់គាត់ក៏បានចាប់ខ្ញុំបោកទៅលើកគ្រែ ខ្ញុំក៏បានរើដែរ ដោយបានធ្លាក់ពីលើគ្រែ ហើយគេចាប់ខ្ញុំបោកលើគ្រែម្ដងទៀត ដោយខ្ញុំ គ្មានកំលាំងតបតក៏ត្រូវគាត់ចាប់រំលោភ ដោយសារមានការចាប់រំលោភ ហើយគាត់បានលួងលោម ថានិងចូលស្ដី ខ្ញុំក៏បានយល់ព្រមមិនប្ដឹងផ្ដល់អ្វីទេ ក្រោយមកគាត់បានចូលស្ដីនាងខ្ញុំមែនតែដោយ សារមិនត្រូវរ៉ូវគ្នា ហើយម្ដាយរបស់គាត់បានទាមទារផ្ដាច់ពាក្យ ទើបនាងខ្ញុំប្ដឹងដើម្បីរកយុត្តិធម៌ និងទាមទារថ្លៃកិត្តិយសនាងខ្ញុំចំនួន ៥.០០០ ដុល្លារ ។ នាងខ្ញុំចាប់ផ្ដើមមានទំនាក់ទំនងស្នេហា ក្រោយពេលមានការចាប់រំលោភ មូលហេតុដែលនាងខ្ញុំឲ្យគាត់ជូនដោយសារបងប្អូននាងខ្ញុំសុទ្ធតែជាស្រី ហើយនាងខ្ញុំទុកចិត្តគាត់ដោយសារគាត់ធ្លាប់ចេញចូលផ្ទះខ្ញុំដូចបងប្អូន ។ ខ្ញុំសូមបដិសេធការអះអាងរបស់ជនជាប់ចោទ ។ មុនពេលកើតហេតុចាប់រំលោភនៅផ្ទះសំណាក់ គ្មានការរួមភេទដូចការអះអាងរបស់គាត់ទេ ។ មានការដើរលេងលក្ខណៈមិត្តភក្ដិ ។ គាត់ធ្លាប់ចាប់រំលោភខ្ញុំម្ដងទៀតនៅផ្ទះរបស់គាត់ នៅពេលចូលឆ្នាំចិន ក្រោយអង្គហេតុដែលនាងខ្ញុំប្ដឹង ។ ថ្ងៃខ្ញុំមកពីភ្នំពេញអ្នកផ្ទះខ្ញុំដឹង ។ នាងខ្ញុំទុកចិត្តដោយសារចាត់ទុកជាបងប្អូន ។ នាងខ្ញុំមកដល់ម៉ោងមួយយប់ ហើយបងប្អូនខ្ញុំសុទ្ធតែជាស្រីៗ ។ នាងខ្ញុំមានទំនាក់ទំនងស្នេហាក្រោយកើតហេតុ ។ នាងខ្ញុំហ៊ានទៅផ្ទះ សំណាក់ដោយសារគាត់អះអាងថា គាត់ជូនខ្ញុំទៅផ្ទះសំណាក់ហើយឲ្យនាងខ្ញុំនៅតែម្នាក់ឯងទើបខ្ញុំជឿ ។ ខ្ញុំទុកចិត្តដោយសារគាត់ចេញចូលផ្ទះខ្ញុំរាប់អានដូចបងប្អូនស្គាល់គ្នាច្បាស់ ។ ខ្ញុំនិយាយជាការពិត ។ ពេលចេញពីផ្ទះសំណាក់នាងខ្ញុំទាមទារឲ្យគាត់ឌុបខ្ញុំទៅផ្ទះ ។ នាងខ្ញុំសុំមិនឆ្លើយនិងសំណួរមេធាវីជនជាប់ចោទបន្ត ។ ពេលខ្ញុំមកពីភ្នំពេញ គាត់ជាអ្នកព្យាយាមទាក់ទងមកខ្ញុំ ។ កន្លងមកជូនខ្ញុំជិះម៉ូតូឌុបជូនអ្នកផ្ទះមកយក ។ គាត់ជាអ្នកនាំខ្ញុំទៅផ្ទះសំណាក់ ដោយសារគាត់ថាឲ្យខ្ញុំនៅផ្ទះសំណាក់តែឯង ។ ពេលទៅផ្ទះសំណាក់គាត់ឡើងផ្ទះសំណាក់មុន ហើយឲ្យខ្ញុំនៅចាំ ដោយសារយូរពេកនាងខ្ញុំបានឡើងទៅឃើញគាត់

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-ជនជាប់ចោទបានឆ្លើយថា ខ្ញុំបានដឹងខ្ញុំជាប់ចោទពីបទ រំលោភសេពសន្ថវៈ ។ កើតហេតុថ្ងៃ**ទី១១ ខែមេសា** ឆ្នាំ២០១៦ ម៉ោង ១២:៣០ នាទីយប់ ដំបូងខ្ញុំនៅផ្ទះហើយឈ្មោះ [redacted] មកពីភ្នំពេញ**បានទូរស័ព្ទ**ហៅខ្ញុំឲ្យទៅទទួល ហើយបានឲ្យខ្ញុំជូនទៅផ្ទះសំណាក់ ដោយគាត់ប្រាប់ថា យប់ហើយ**មិនបាន**ប្រាប់អ្នកផ្ទះ ។ ខ្ញុំទៅយកនៅបេនឡានកាពីតូលផ្សារភូពុយ ។ ខ្ញុំបានឡើងលើផ្ទះសំណាក់**ជាមួយ**គាត់ដោយខ្ញុំបានជួយកាន់អីវ៉ាន់ដៃទាំងពីរ លុះដល់ម៉ោងបួនភ្លឺ ខ្ញុំបានជូនគាត់ទៅផ្ទះវិញ ។ ទំនាក់ទំនងគឺចេញចូលផ្ទះគ្នាដោយស្គាល់គ្នារយៈពេល ៥ឆ្នាំហើយ លក្ខណៈសង្សារ ។ មូលហេតុដោយសារនៅក្នុងឆ្នាំ២០១៧ ខ្ញុំបានប្រាប់ចាស់ទុំខាងខ្ញុំដើម្បីចូលស្តីនាង តែខ្ញុំមានលទ្ធភាពត្រឹមតែ ២.៥០០ ដុល្លារ ហើយខាងស្រីទាមទារដល់ ៤.៥០០ ដុល្លារអាមេរិក ហើយចុងក្រោយខាងខ្ញុំមានលទ្ធភាពត្រឹម ៣.២០០ ដុល្លារ ហើយខាងគាត់ទាមទារ ៣.៥០០ ដុល្លារ ទើបមិនត្រូវគ្នា ។ នៅថ្ងៃកើតហេតុជាការរួមភេទដោយការព្រមព្រៀងពុំមានការបង្ខំទេ ព្រោះកន្លងមកមានការរួមភេទលក្ខណៈគ្រួសារទៅហើយ ។ សម្រាប់ខ្ញុំនៅតែស្រលាញ់គាត់ពុំមានប្រួលប្រែ ។ កន្លងមកគាត់បានប្តឹងទៅខាងស្នងការ ប៉ុន្តែពុំមានការឃាត់ខ្លួនទេ ដោយគេប្រាប់ថា ពុំមានភស្តុតាង ។ ខ្ញុំស្គាល់គ្នាប្រាំឆ្នាំ តែទំនាក់ទំនងរួមភេទទើបតែមានជាងមួយឆ្នាំ ភស្តុតាងបញ្ជាក់ពីទំនាក់ទំនងស្នេហាពីមុនមាន។ ខ្ញុំទៅយកគាត់នៅបេនឡានម៉ោង ១២៖៣០ នាទីយប់ ។ គាត់ប្រាប់ខ្ញុំថា ទៅផ្ទះសំណាក់ទៅ ព្រោះគាត់ថាមិនបានប្រាប់អ្នកផ្ទះ ។ គោលបំណងខ្ញុំទទួលយកគាត់ហើយជូនទៅផ្ទះ ។ ប៉ូលីសប្រាប់ថារឿងប្តឹងនៅស្នងការនេះជារឿងត្រូវរ៉ូវគ្នា ។ ក្រោយពេលមិនត្រូវរ៉ូវគ្នាគាត់ បានផុសតាមហ្វេសបុកមើលងាយខ្ញុំ និងក្រុមគ្រួសារ ។ ចំពោះការជេរប្រមាថមើលងាយនេះខ្ញុំក៏បានប្តឹងនៅតុលាការនេះដែរ ។ ពេលចុះពីផ្ទះសំណាក់វិញ ខ្ញុំបានជូនទៅផ្ទះ ពុំមានការឆោឡោអ្វីទេ ៣ឆ្នាំក្រោយ ទើបមានបណ្តឹង ។ ការដែលគាត់បញ្ជាក់ថាខ្ញុំឡើងទៅលើផ្ទះសំណាក់មុន ហើយគាត់ចាំ ១៥នាទី មិនជាការពិតទេ គឺឡើងដំណាលគ្នា ។ ខ្ញុំសូមបញ្ជាក់ថា ថ្ងៃឡើងផ្ទះសំណាក់បានអោបថើប ក្រោយមកទើបរួមភេទ ។

-ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា ជនជាប់ចោទឆ្លើយទាំងបំពានទាំងមិនមែនជាការពិត ខ្ញុំស្គាល់គ្នារយៈពេល ១ឆ្នាំ រាប់អានគ្នាជាលក្ខណៈបងប្អូនមិត្តភក្តិធម្មតា មិនមានការរួមភេទដូចគាត់ឆ្លើយទេ លើកលែងតែនៅថ្ងៃកើតហេតុ គឺគាត់ជាអ្នកទូរស័ព្ទមកសួរអំពីការធ្វើ ដំណើររបស់ខ្ញុំ គឺគាត់

[redacted]

-តាមចម្លើយរបស់ជនជាប់ចោទ, ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ [redacted] មានភាពស៊ីសង្វាក់គ្នាបញ្ជាក់បានថា នៅថ្ងៃកើតហេតុជនជាប់ចោទពិតជាបានទទួលជនរងគ្រោះពីបេនឡាន ហើយជូនទៅផ្ទះសំណាក់ថាឲ្យដេកតែឯង តែជនជាប់ចោទបែរជាឆ្លៀតឱកាសនេះចូលទៅក្នុងបន្ទប់ ហើយចាប់ជនរងគ្រោះរួមភេទរហូតបានសម្រេច ព្រមទាំងបានលួងលោមជនរងគ្រោះ ដើម្បីកុំឲ្យមានការប្ដឹងផ្ដល់ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់បុរីថ្មី ភូមិអូរតាគាំ១ សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៦ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីទាមទារសំណងចំនួន ៥ ០០០ (ប្រាំពាន់) ដុល្លារអាមេរិក គប្បីតុលាការពិចារណាលើភាពជាក់ស្ដែង ។

## ហេតុដូច្នេះសម្រេច

១-ផ្ដន្ទាទោសលើឈ្មោះ [redacted] ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ (សាវតាជាតិគ្រប់គ្រាន់ខាងលើ) ដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ) ឆ្នាំ ពីបទ រំលោភសេពសន្ថវៈ តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់បុរីថ្មី ភូមិអូរតាគាំ១ សង្កាត់ទួលតាឯក ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ។

២-ឲ្យឈ្មោះ [redacted] សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៨ ០០០ ០០០ (ប្រាំបីលាន) រៀល ឲ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ការទាមទារលើសពីនេះច្រានចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។

-ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ក្រុមប្រឹក្សាជំនុំជម្រះ**

**១-ប្រធានក្រុមប្រឹក្សា**

[redacted]

**២-ចៅក្រមប្រឹក្សា**

[redacted]

**៣-ចៅក្រមប្រឹក្សា**

[redacted]

[redacted]